វិទ្យាស្ថានសភាកម្ពុជា
PARLIAMENTARY INSTITUTE OF CAMBODIA
STRENGTHENING PARLIAMENTARY CAPACITY

# ព្រឹត្តប័ត្រព័ត៌មានសង្ខេប

**សប្ដាហ៍ដែលបញ្ចប់**
**ថ្ងៃទី០២ ខែសីហា ឆ្នាំ២០១៩**

ចំណុចសំខាន់ៗ អំពីព័ត៌មានសេដ្ឋកិច្ច និងការអភិវឌ្ឍសារពើពន្ធនៅក្នុងបណ្ដាប្រទេសជាសមាជិកអាស៊ាន និងនៅប្រទេសផ្សេងៗទៀត នៅក្នុងសប្ដាហ៍នេះគឺ៖

- វិស័យធនាគារនៅកម្ពុជាមានដំណើរការល្អនៅក្នុងឆ្នាំ២០១៩
- រូបិយប័ណ្ណរបស់ប្រទេសថៃកាន់តែរឹងមាំ គំរាមកំហែងដល់សេដ្ឋកិច្ច
- ធនាគារជាតិរបស់អាមេរិកទម្លាក់អត្រាការប្រាក់នៅក្នុង "ការកែតម្រូវនៅពាក់កណ្ដាលនៃវដ្ដ"

*ព្រឹត្តប័ត្រសង្ខេបព័ត៌មាននេះគឺជាព្រឹត្តិប័ត្រប្រចាំសប្ដាហ៍ដែលរៀបចំឡើងដើម្បីតាមដានព័ត៌មានអំពីការអភិវឌ្ឍសេដ្ឋកិច្ច និងសារពើពន្ធថ្មីៗនៅក្នុងប្រទេសកម្ពុជា និងដៃគូពាណិជ្ជកម្មនានា។ ឯកសារនេះត្រូវបានធ្វើឡើងដោយក្រុមការងារបណ្ដុះបណ្ដាលសមត្ថភាពការវិភាគសារពើពន្ធរបស់វិទ្យាស្ថានសភាកម្ពុជា ក្នុងគោលបំណងពង្រឹងជំនាញនៃការធ្វើឯកសារ និងការស្រាវជ្រាវរបស់ខ្លួន។ ការងារនេះត្រូវបានព្យាយាមធ្វើឡើងដើម្បីអោយការវិភាគ និងអត្ថន័យ ដែលបានផ្ដល់នៅក្នុងឯកសារនេះមានគុណភាពខ្ពស់។ ទោះជាយ៉ាងណាក៏ដោយ សូមអ្នកអានចាត់ទុកឯកសារនេះជាផ្នែកមួយនៃលំហាត់អនុវត្តន៍នៅក្នុងកំឡុងពេលនៃការបណ្ដុះបណ្ដាល។ យើងមិនអាចធានាថាឯកសារនេះល្អឥតខ្ចោះនោះទេ។*

## ព័ត៌មាន និងទិន្នន័យអំពីប្រទេសកម្ពុជា

### វិស័យធនាគារនៅកម្ពុជា មានប្រតិបត្តិការល្អប្រសើរនៅក្នុងឆ្នាំ២០១៩

យោងទៅតាមសេចក្ដីប្រកាសព័ត៌មាន ស្ដីពី សន្និបាតបូកសរុបលទ្ធផលការងារឆមាសទី១ របស់ធនាគាជាតិនៃកម្ពុជា បានឲ្យដឹងថា វិស័យធនាគារ និងហិរញ្ញវត្ថុបានរីកចម្រើនជាលំដាប់ក្នុងឆមាសទី១ក្នុងឆ្នាំនេះ និងបានចូលរួមចំណែកក្នុងការជំរុញកំណើនសេដ្ឋកិច្ច។

ទ្រព្យសកម្មវិស័យធនាគារ និងហិរញ្ញវត្ថុ បានកើនឡើង ១៩,២%ធៀបទៅនឹងឆមាសទី១ក្នុងឆ្នាំ២០១៨ ដែលឈានទៅដល់១៦៦%នៃផ.ស.ស។ ដំណើរការឥណទានត្រូវបានបន្តមានលក្ខណៈល្អប្រសើរ ជាមួយអត្រានៃឥណទានមិនដំណើរការ ២,៣%សម្រាប់ធនាគារ និង១,១%សម្រាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។

ដើម្បីរក្សាបានស្ថេរភាពហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជា បានបន្តពង្រឹងការត្រួតពិនិត្យទៅលើហានិភ័យ និងកែលម្អក្របខ័ណ្ឌរបស់ខ្លួន សម្រាប់ការគ្រប់គ្រងទស្សនវិស័យសេដ្ឋកិច្ចកម្ពុជា ការដាក់ចេញនូវវិធានការម៉ាក្រូ និងមីក្រូ វិធានការកិច្ចការពារអតិថិជន និងលើកកម្ពស់ការយល់ដឹងផ្នែកហិរញ្ញវត្ថុ។

### តារាងប្រចាំសប្ដាហ៍៖ ចំណាយថវិកាជាតិ

តារាងប្រចាំសប្ដាហ៍នេះ បង្ហាញពីកំណើននៃចំណាយថវិកាថ្នាក់ជាតិសរុប នៅក្នុងខែមិថុនានិង ក្នុងត្រីមាសទី២ ឆ្នាំ ២០១៩ ដោយធៀបទៅនឹងអំឡុងពេលដូចគ្នានៅឆ្នាំមុន។

**ចំណាយថវិកា នៅក្នុងខែមិថុនា និងត្រីមាសទី២ ឆ្នាំ២០១៩**

| គិតជាប៊ីលានរៀល | ខែមិថុនា | | | ត្រីមាសទី២ | | |
|---|---|---|---|---|---|---|
| | 2018 | 2019 | កំណើន | 2018 | 2019 | កំណើន |
| **ចំណាយសរុប** | **1,657** | **1,576** | **-5%** | **4,706** | **4,931** | **5%** |
| ***ចំណាយមូលធន*** | ***1,102*** | ***1,270*** | ***15%*** | ***3,188*** | ***3,724*** | ***17%*** |
| ចំណាយប្រាក់ខែ | 694 | 655 | -6% | 1,911 | 1,963 | 3% |
| ចំណាយមិនមែនប្រាក់ខែ | 408 | 615 | 51% | 1,277 | 1,761 | 38% |
| ***ចំណាយមូលធន*** | ***555*** | ***306*** | ***-45%*** | ***1,518*** | ***1,207*** | ***-21%*** |
| ហិរញ្ញប្បទានក្នុងស្រុក | 144 | 159 | 10% | 484 | 414 | -15% |
| ហិរញ្ញប្បទានក្រៅស្រុក | 411 | 147 | -64% | 1,033 | 793 | -23% |

ប្រភព៖ ToEF ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ចំណាយថវិកាថ្នាក់ជាតិជាក់ស្តែង មានការធ្លាក់ចុះ៥% ធៀបទៅនឹងរយៈពេលមួយឆ្នាំមុន ពោលគឺពី ១ ៦៥៧ ប៊ីលានរៀល (មិថុនា ឆ្នាំ២០១៨) មកត្រឹម ១ ៥៧៦ ប៊ីលានរៀល (មិថុនា ឆ្នាំ២០១៩)។ ការធ្លាក់ចុះនៃចំណាយនេះគឺបណ្តាលមកពីការធ្លាក់ចុះនៃចំណាយមូលធន ដែលក្នុងនោះផ្នែកហិរញ្ញប្បទានក្រៅប្រទេសធ្លាក់ចុះ៦៤% និងការធ្លាក់ចុះនៃចំណាយប្រាក់ខែចំនួន ៦%។

ទោះបីជាយ៉ាងណាក៏ដោយ ចំណាយសរុបសម្រាប់ត្រីមាសទី២ បានកើនឡើង៥% គិតជាទឹកប្រាក់ ៤ ៩៣១ ប៊ីលានរៀល ធៀបទៅនឹងឆ្នាំមុនដែលមានចំនួន ៤ ៧០៦ ប៊ីលានរៀល ក្នុងត្រីមាសដូចគ្នាកាលពីឆ្នាំមុន។ ការកើនឡើងនេះគឺដោយសារចំណាយមិនមែនប្រាក់ខែបានកើនឡើងប្រមាណ ៣៨%។

## ព័ត៌មាន និងទិន្នន័យរបស់បណ្តាប្រទេសនៅក្នុងអាស៊ាន និងដៃគូពាណិជ្ជកម្មដទៃទៀត

### រូបិយប័ណ្ណរបស់ប្រទេសថៃកាន់តែរឹងមាំ និងគំរាមកំហែងដល់សេដ្ឋកិច្ច

តម្លៃនៃប្រាក់បាតថៃបានកើនឡើងគួរឲ្យកត់សម្គាល់បើធៀបទៅនឹងប្រាក់ដុល្លារក្នុងឆ្នាំ២០១៩ ដែលកើនឡើងលឿនជាងរូបិយប័ណ្ណនៃប្រទេសដែលកំពុងរីកលូតលាស់។ ចាប់តាំងពីដើមឆ្នាំនេះ ប្រាក់បាតថៃបានកើនតម្លៃ៥% ធៀបទៅនឹងប្រាក់ដុល្លារអាមេរិក និងបានកើនឡើង៨% បើធៀបនឹងរយៈពេលមួយឆ្នាំមុន។

ក្រុមអ្នកនយោបាយ អ្នកវិភាគ និងអ្នកនាំចេញបានបង្ហាញក្តីបារម្ភទៅលើបញ្ហានេះថា ការកើនឡើងតម្លៃរូបិយប័ណ្ណនេះនឹងជះឥទ្ធិពលអវិជ្ជមានដល់ការប្រកួតប្រជែងសេដ្ឋកិច្ចដែលកំពុងស្ថិតនៅក្នុងស្ថានភាពទន់ខ្សោយស្រាប់ នេះបើយោងទៅតាមសារព័ត៌មាន CNBC ។ ការសិក្សាមួយដែលធ្វើដោយធនាគារនៃរាជាណាចក្រថៃបានបង្ហាញថា សម្រាប់ការកើនឡើង ១%នៃប្រាក់បាតធៀបទៅនឹងប្រាក់ដុល្លារ តម្លៃនៃការនាំចេញកើនឡើងប្រមាណ០,៣%។ ការនាំចេញបានធ្លាក់ចុះទៅហើយ ប្រឈមនឹងការកើនឡើងថ្លៃរូបិយប័ណ្ណបីខែជាប់ៗគ្នាកន្លងមកនេះ ហើយក្នុងខែឧសភា ការនាំចេញធ្លាក់ចុះ៥,៨% ធៀបទៅនឹងខែឧសភា ឆ្នាំ២០១៨។ ក្រុមអ្នកវិភាគបានរំពឹងថានឹងមានការធ្លាក់ចុះត្រឹមតែ ៣,៦%ប៉ុណ្ណោះ។

## សេដ្ឋកិច្ចពិភពលោក

### ធនាគារជាតិរបស់អាមេរិកទម្លាក់អត្រាការប្រាក់នៅក្នុង "ការកែតម្រូវនៅពាក់កណ្តាលនៃវដ្ត"

កាលពីថ្ងៃពុធ គណៈកម្មាធិការសហព័ន្ធទីផ្សារបើកទូលាយបានបោះឆ្នោតដើម្បីគាំទ្រអោយបន្ថយអាត្រាការប្រាក់គោលនៃកំចី ពី២,៥% មកត្រឹម២% ដែលជាការកាត់បន្ថយដំបូងគិតពីឆ្នាំ២០០៨។ ក្នុងអំឡុងកិច្ចសន្និសីទសារព័ត៌មាន លោកប្រធាន Jerome Powell បាននិយាយថា ការបញ្ចុះអត្រានេះគឺជាជំហ៊ានកំពុងបន្តមួយដើម្បីជំរុញសេដ្ឋកិច្ច និងបង្កើនអតិផរណា ហើយនេះគ្រាន់តែជាការកែតម្រូវគោលនយោបាយនៅអំឡុងពេលពាក់កណ្តាលនៃវដ្តតែប៉ុណ្ណោះ។ លោកបានបន្ថែមទៀតថា មិនមានភាពច្បាស់លាស់នៃការបន្ថយអត្រាបន្ថែមទៀតនាពេលអនាគតឡើយ។

## ព័ត៌មានសម្រាប់សប្តាហ៍បន្ទាប់

ទិន្នន័យសម្រាប់សប្តាហ៍ខាងមុខនេះ រួមមាន៖ ការសម្រេចចិត្តទៅលើអត្រាការប្រាក់នៅប្រទេសថៃ និងហ្វីលីពីន និងការប៉ាន់ប្រមាណទៅលើផ.ស.ស.របស់ប្រទេសឥណ្ឌូនេស៊ី ហ្វីលីពីន និងជប៉ុន ។ ខាងក្រោមគឺជាប្រតិទិនពេញលេញនៃការចេញនូវទិន្នន័យ និងការអភិវឌ្ឍ ដែលក្រុម FACT នឹងបន្តតាមដាននៅសប្តាហ៍ក្រោយ៖

ថ្ងៃចន្ទ ទី០៥ ខែសីហា

- ផ.ស.ស.របស់ឥណ្ឌូនេស៊ី សម្រាប់ត្រីមាសទី២ ឆ្នាំ២០១៩
- ប្រាក់បម្រុងរូបិយបណ្ណបរទេសនៅកូរ៉េខាងត្បូង សម្រាប់ខែកក្កដា
- សន្ទស្សន៍គ្រប់គ្រងការបញ្ជាទិញនៅសឹង្ហបុរី ដែលចេញផ្សាយដោយក្រុមហ៊ុនMarkit សម្រាប់ខែកក្កដា
- សន្ទស្សន៍គ្រប់គ្រងការបញ្ជាទិញនៅអាមេរិក ដែលចេញដោយក្រុមហ៊ុនMarkit ចុងក្រោយសម្រាប់ខែកក្កដា
- សន្ទស្សន៍គ្រប់គ្រងការបញ្ជាទិញសេវាកម្ម នៅអាមេរិក ដែលធ្វើដោយក្រុមហ៊ុនMarkit ចុងក្រោយសម្រាប់ខែកក្កដា

ថ្ងៃអង្គារ ទី០៦ ខែសីហា

- ការលក់យានយន្តសរុបនៅអាមេរិក សម្រាប់ខែកក្កដា
- គណនីចរន្តរបស់កូរ៉េខាងត្បូង សម្រាប់ខែមិថុនា
- ចំណាយប្រចាំគ្រួសារនៅជប៉ុន សម្រាប់ខែមិថុនា
- ភាពជឿជាក់របស់អ្នកប្រើប្រាស់នៅឥណ្ឌូនេស៊ី សម្រាប់ខែកក្កដា
- អត្រាអតិផរណារបស់ហ្វីលីពីន សម្រាប់ខែកក្កដា
- អត្រានិកម្មភាពនៅថៃ សម្រាប់ខែកក្កដា
- អង្កេត ការងារដែលនៅទំនេរ/ចំហរ (JOLTs) របស់អាមេរិក សម្រាប់ខែមិថុនា

ថ្ងៃពុធ ទី០៧ ខែសីហា

- សេចក្តីសង្ខេបគំនិតយោបល់របស់ធនាគារជប៉ុន
- តុល្យភាពពាណិជ្ជកម្មនៅហ្វីលីពីន សម្រាប់ខែមិថុនា
- ការសម្រេចទៅលើអត្រាការប្រាក់របស់ថៃ
- ទុនបម្រុងរូបិយប័ណ្ណបរទេសរបស់សឹង្ហបុរី សម្រាប់ខែកក្កដា
- ទុនបម្រុងរូបិយប័ណ្ណបរទេសរបស់ហ្វីលីពីន សម្រាប់ខែកក្កដា

ថ្ងៃព្រហស្បតិ៍ ទី០៨ ខែសីហា

- គណនីចរន្តរបស់ជប៉ុន សម្រាប់ខែមិថុនា
- ផ.ស.ស. របស់ហ្វីលីពីន នៅត្រីមាសទី២ ឆ្នាំ២០១៩
- សមតុល្យពាណិជ្ជកម្មរបស់ចិន សម្រាប់ខែកក្កដា
- ទំនុកចិត្តអ្នកប្រើប្រាស់នៅប្រទេសថៃ សម្រាប់ខែកក្កដា
- ការលក់រាយនៅសឹង្ហបុរី សម្រាប់ខែមិថុនា
- ការសម្រេចចិត្តលើអត្រាការប្រាក់របស់ហ្វីលីពីន
- ការលក់រាយរបស់ឥណ្ឌូនេស៊ី សម្រាប់ខែមិថុនា

ថ្ងៃសុក្រ ទី០៩ ខែសីហា

- ការប៉ាន់ស្មានផ.ស.ស.ដំបូងរបស់ជប៉ុន សម្រាប់ត្រីមាសទី២ ឆ្នាំ២០១៩
- អត្រាអតិផរណានៅចិន សម្រាប់កក្កដា
- ទុនបម្រុងរូបិយប័ណ្ណបរទេសនៅថៃ សម្រាប់ខែកក្កដា
- ផលិតកម្មឧស្សាហកម្មនៅម៉ាឡេស៊ី សម្រាប់ខែមិថុនា
- និកម្មភាពនៅម៉ាឡេស៊ី សម្រាប់ខែមិថុនា